**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

លេខ ២៥៦ ប្រក. កសក-ប

# ប្រកាស
# ស្តីពី
# ការរៀបចំ និងប្រព្រឹត្តទៅរបស់ការិយាល័យ ចំណុះឧទ្យានសួនសត្វ និងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅ

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញអនុក្រឹត្យលេខ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១០៥ អនក្រ.បក ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានផែនការ និងស្ថិតិ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងមជ្ឈមណ្ឌលព័ត៌មាននិងឯកសារកសិកម្មចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផលឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន



អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទលេខ :(០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Nº 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia.
Phone : (023) 726 128 / 726 129, Fax : (855) 23 - 217 320

ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រនិងកែលម្អដីកសិកម្មឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងកែសម្រួលអគ្គនាយកដ្ឋានចំការកៅស៊ូ ទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួងស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ២២៤ អនក្រ.បក ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៦ ស្តីពីការដំឡើងនាយកដ្ឋានផលិតកម្មនិងបសុព្យាបាលទៅជាអគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ
- បានឃើញប្រកាសលេខ៥០៩ ប្រក.កសក.បុ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០៣ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់រដ្ឋបាលព្រៃឈើ
- បានឃើញប្រកាសលេខ៦០២ ប្រក.កសក.ប ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យ និងអង្គភាពចំណុះនាយកដ្ឋាន វិទ្យាស្ថាន និងឧទ្យានសួនសត្វ និងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅនៃរដ្ឋបាលព្រៃឈើ
- បានឃើញប្រកាសលេខ៦០៩ ប្រក.កសក ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៦ ស្តីពីការប្តូរឈ្មោះមន្ទីរកសិកម្មរាជធានី ខេត្ត និងការដាក់បញ្ចូលខណ្ឌរដ្ឋបាលព្រៃឈើ និងខណ្ឌរដ្ឋបាលជលផល ឲ្យស្ថិតក្រោមមន្ទីរកសិកម្មរាជធានី ខេត្ត
- យោងលិខិតលេខ៩៤៣ មស.នក ចុះថ្ងៃសុក្រ ១រោច ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៨ របស់ក្រសួងមុខងារសាធារណៈ ស្តីពីការឯកភាពលើការរៀបចំប្រកាសស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់ការិយាល័យចំណុះឧទ្យានសួនសត្វនិងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅ នៃរដ្ឋបាលព្រៃឈើ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សម្រេច

**ប្រការ១ ._**

ឧទ្យានសួនសត្វ និងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅជាអង្គភាពចំណុះរដ្ឋបាលព្រៃឈើនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានថ្នាក់ស្មើនឹងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត មានតួនាទី ភារកិច្ចដូចខាងក្រោមៈ

- រៀបចំផែនការយុទ្ធសាស្ត្រផែនការសកម្មភាពប្រចាំឆ្នាំ និងគម្រោងថវិកាប្រចាំឆ្នាំសម្រាប់ដំណើរការគ្រប់គ្រងឧទ្យានសួនសត្វនិងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅ
- ទំនាក់ទំនង និងសហការសម្របសម្រួលការងារជាមួយស្ថាប័នពាក់ព័ន្ធ អង្គការជាតិ និងអន្តរជាតិនានា ដើម្បីស្វែងរកថវិកាសម្រាប់ដំណើរការឧទ្យានសួនសត្វនិងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅ
- ផ្តល់សេវាកម្មសង្គ្រោះ ព្យាបាល ថែទាំ និងជ្រើសរើសបង្កាត់ពូជសត្វព្រៃគ្រប់ប្រភេទ
- ប្រមូលទិន្នន័យ និងផលិតឯកសារវិទ្យាសាស្ត្រពាក់ព័ន្ធនឹងសត្វព្រៃ
- សិក្សាស្រាវជ្រាវលក្ខណៈវិទ្យាសាស្ត្រសត្វព្រៃគ្រប់ប្រភេទ
- គ្រប់គ្រងសាមន្ទីរព្រៃឈើ និងសត្វព្រៃ សាលបណ្តុះបណ្តាល ផ្សព្វផ្សាយ និងទំនាក់ទំនងសាធារណៈ
- រក្សាសន្តិសុខសណ្តាប់ធ្នាប់ថែរក្សាអនាម័យ និងគ្រប់គ្រងចំណូលចំណាយនៅក្នុងឧទ្យានសួនសត្វ និងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅ
- អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងសោភ័ណភាពនៅឧទ្យានសួនសត្វ និងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅ

- បង្កើត និងគ្រប់គ្រងបណ្តាញទំនាក់ទំនងជាមួយបណ្តាសួនសត្វនានានៅក្នុងនិងក្រៅប្រទេស
- រៀបចំកម្មវិធីដោះលែងសត្វព្រៃទៅក្នុងដែនជម្រកធម្មជាតិ
- សិក្សាលទ្ធភាពបង្កើតមជ្ឈមណ្ឌលសង្គ្រោះ និងស្តារលទ្ធភាពសត្វព្រៃឡើងវិញ
- គ្រប់គ្រងសត្វព្រៃដែលរឹបអូសបានពីបទល្មើសសត្វព្រៃ និងសត្វព្រៃអំណោយពីសប្បុរសជន
- រៀបចំបែបបទអនុញ្ញាត និងគោលការណែនាំសម្រាប់ការចិញ្ចឹមសត្វព្រៃជាលក្ខណៈគ្រួសារ និងសួន សត្វនានា
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំស្តីពីសកម្មភាព និងលទ្ធផលការងាររបស់ឧទ្យានសួនសត្វនិងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅជូនប្រធានរដ្ឋបាលព្រៃឈើ
- ទទួលភារកិច្ចផ្សេងទៀតដែលប្រធានរដ្ឋបាលព្រៃឈើប្រគល់ជូន។

ឧទ្យានសួនសត្វ និងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅដឹកនាំដោយប្រធានមួយរូប និងអមដោយអនុប្រធានមួយចំនួនជាជំនួយការ។

**ប្រការ២ ._**

ឧទ្យានសួនសត្វ និងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅមានការិយាល័យចំណុះចំនួន០៥ដែលមានថ្នាក់ស្មើការិ-យាល័យចំណុះមន្ទីរជំនាញនៅរាជធានី ខេត្ត មានដូចតទៅ៖

- ការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ
- ការិយាល័យអភិរក្ស និងវិបុលកម្ម
- ការិយាល័យស្រាវជ្រាវ អប់រំផ្សព្វផ្សាយ និងសហប្រតិបត្តិការអន្តរជាតិ
- ការិយាល័យសង្គ្រោះ និងព្យាបាល
- ការិយាល័យសេវាកម្ម និងទេសចរណ៍ ។

**ប្រការ៣ ._**

តួនាទី ភារកិច្ចរបស់ការិយាល័យចំណុះឧទ្យានសួនសត្វ និងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅមានដូចខាងក្រោម ៖

**៣.១-ការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ**

- រៀបចំ និងអនុវត្តផែនការយុទ្ធសាស្រ្ត ផែនការសកម្មភាព និងគម្រោងថវិកាសម្រាប់ការងាររដ្ឋបាល និងហិរញ្ញវត្ថុ
- ទទួល បញ្ជូនលិខិត ចុះបញ្ជិការ ថតចម្លងឯកសារផ្សព្វផ្សាយដល់បណ្តាការិយាល័យក្រោមឱវាទឧទ្យានសួនសត្វ និងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅ
- គ្រប់គ្រងបន្ទប់ប្រជុំរៀបចំពិធីផ្លូវការ បុណ្យជាតិ និងអន្តរជាតិ
- គ្រប់គ្រងការងារសន្តិសុខសណ្តាប់ធ្នាប់និងអនាម័យឧទ្យានសួនសត្វនិងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅ
- គ្រប់គ្រងស្ថិតិមន្ត្រីរាជការបុគ្គលិក កម្មករ ឯកសារគ្រប់ប្រភេទ និងអភិវឌ្ឍន៍ធនធានមនុស្ស
- គ្រប់គ្រងចំណូល-ចំណាយថវិកាឧទ្យានសួនសត្វ និងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅ
- រៀបចំចងក្រងបញ្ជីសារពើភណ្ឌ និងគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋរបស់ឧទ្យានសួនសត្វនិងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅ
- រៀបចំផែនការថវិកាប្រចាំឆ្នាំ ផែនការសកម្មភាពតាមកម្មវិធី

- រៀបចំផែនការយុទ្ធសាស្ត្រផែនការសកម្មភាពប្រចាំឆ្នាំសម្រាប់ដំណើរការឧទ្យានសួនសត្វ និងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅ
- គ្រប់គ្រង និងផ្គត់ផ្គង់មធ្យោបាយ សម្ភារបរិក្ខារ ប្រេងឥន្ធនៈដល់អង្គភាពក្រោមឱវាទឧទ្យានសួនសត្វ និងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅ
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំស្តីពីសកម្មភាព និងលទ្ធផលការងាររបស់ឧទ្យានសួនសត្វ និងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅ
- ទទួលភារកិច្ចផ្សេងទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

**៣.២-ការិយាល័យអភិរក្ស និងវិបុលកម្ម**

- រៀបចំ និងអនុវត្តផែនការយុទ្ធសាស្ត្រផែនការសកម្មភាព និងគម្រោងថវិកាសម្រាប់ការងារអភិរក្ស និងវិបុលកម្មសត្វព្រៃ
- គ្រប់គ្រងឃ្លាំងចំណីផលិតចំណីធម្មជាតិ (ដាំដុះរុក្ខជាតិចំណីសត្វ បង្កាត់ជង្កូវ ចង្រិត កណ្តូប...) ផ្គត់ផ្គង់ និងបែងចែកចំណីទៅតាមប្រភេទសត្វព្រៃនីមួយៗ និងថែរក្សាចំណីបំរុងក្នុងលក្ខខណ្ឌសមស្រប
- គ្រប់គ្រងសត្វព្រៃរឹបអូសបានពីបទល្មើសសត្វព្រៃ និងសត្វព្រៃអំណោយពីសប្បុរសជន
- រៀបចំទ្រុងឬទីហ៊ុំព័ទ្ធសម្រាប់ដាក់បង្ហាញ ឬបង្កាត់ពូជសត្វព្រៃគ្រប់ប្រភេទនៅលើទីតាំងសមស្របតាមលក្ខណៈជីវសាស្ត្រនៃប្រភេទសត្វព្រៃនីមួយៗ
- រៀបចំកម្មវិធីផ្តល់បន្ថែមនូវសារជាតុរ៉ែ និងវីតាមីនដល់សត្វព្រៃគ្រប់ប្រភេទ
- គ្រប់គ្រងស្ថិតិសត្វព្រៃ និងរៀបចំកម្មវិធីបង្កាត់ពូជសត្វព្រៃគ្រប់ប្រភេទ
- បនា្ទុំសត្វព្រៃ និងរៀបចំតុបតែងលំហាត់ប្រាណសត្វព្រៃតាមបណ្តាទ្រុងឬទីហ៊ុំព័ទ្ធ
- រៀបចំកម្មវិធីលែងសត្វព្រៃដែលទទួលជោគជ័យពីកម្មវិធីសង្គ្រោះ បង្កាត់ពូជ និងស្តារលទ្ធភាពជីវសាស្ត្រទៅក្នុងដែនព្រៃធម្មជាតិវិញ
- សិក្សាពីលទ្ធភាពបង្កើតមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃ និងស្តារលទ្ធភាពសត្វព្រៃឡើងវិញ
- រៀបចំបែបបទអនុញ្ញាត និងគោលការណ៍ណែនាំសម្រាប់ការចិញ្ចឹមសត្វព្រៃជាលក្ខណៈគ្រួសារនិងសួនសត្វ
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំស្តីពីសកម្មភាព និងលទ្ធផលការងាររបស់ការិយាល័យជូនប្រធានឧទ្យានសួនសត្វ និងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅ
- ទទួលភារកិច្ចផ្សេងទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

**៣.៣-ការិយាល័យស្រាវជ្រាវ អប់រំផ្សព្វផ្សាយ និងសហប្រតិបត្តិការអន្តរជាតិ**

- រៀបចំ និងអនុវត្តផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព និងគម្រោងថវិកាសម្រាប់ការងារ ស្រាវជ្រាវ អប់រំផ្សព្វផ្សាយ និងសហប្រតិបត្តិការអន្តរជាតិ
- សិក្សាស្រាវជ្រាវពីលក្ខណៈជីវសាស្ត្រសត្វព្រៃ ទីជម្រកធម្មជាតិ ការបន្តពូជ អេកូឡូស៊ី និងប្រភេទចំណីអាហារសត្វព្រៃ
- សិក្សាស្រាវជ្រាវពីលក្ខណៈរូប សេនេទិចសត្វព្រៃ និងជំងឺឆ្លង
- កំណត់អត្តសញ្ញាណកម្មសត្វព្រៃប្រភេទថ្មីដោយសហការជាមួយសារមន្ទីរសត្វព្រៃនានា
- ផលិតខ្សែវីដេអូ ទស្សនាវដ្តី សៀវភៅស្តើង ព្រឹត្តិប័ត្រព័ត៌មាន សៀវភៅរឿងខ្លីៗពាក់ព័ន្ធនឹងសត្វព្រៃ និងព្រៃឈើ
- គ្រប់គ្រងសារមន្ទីរព្រៃឈើ និងសត្វព្រៃ ថែរក្សាសំណាកសត្វព្រៃ និងឈើគ្រប់ប្រភេទ

- គ្រប់គ្រងសាលបណ្តុះបណ្តាលអប់រំផ្សព្វផ្សាយ
- រៀបចំស្លាកសញ្ញា ស្លាករូបភាព
- រៀបចំកម្មវិធីផ្សព្វផ្សាយអប់រំអំពីសត្វព្រៃ និងព្រៃឈើ
- ផ្សព្វផ្សាយសកម្មភាពការងារអភិរក្សសត្វព្រៃ និងព្រៃឈើតាមប្រព័ន្ធផ្សព្វផ្សាយផ្សេងៗ
- បង្កើត និងគ្រប់គ្រងបណ្តាញទំនាក់ទំនងជាមួយបណ្តាសួនសត្វក្នុង និងក្រៅប្រទេស
- ធ្វើទំនាក់ទំនង និងសម្របសម្រួលលើការងារសហប្រតិបត្តិការអន្តរជាតិជាមួយទីភ្នាក់ងារ ស្ថាប័ន អង្គការអន្តរជាតិ សង្គមស៊ីវិល និងអង្គការក្រៅរដ្ឋាភិបាលនានា
- ពិនិត្យតាមដាន និងវាយតម្លៃលើការអនុវត្តអនុស្សរណៈនិងកិច្ចព្រមព្រៀងរវាងឧទ្យានសួនសត្វ និងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅ និងដៃគូសហប្រតិបត្តិការនានា
- សម្របសម្រួលរៀបចំបែបបទសម្រាប់មន្ត្រីឧទ្យានសួនសត្វ និងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅចូលរួមប្រជុំថ្នាក់ជាតិ ឬអន្តរជាតិ
- រៀបចំកម្មវិធីអង្គាសប្រាក់ ឬគម្រោងស្នើថវិកាពីអង្គការក្រៅរដ្ឋាភិបាល ស្ថាប័នជាតិ និងអន្តរជាតិ
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំស្តីពីសកម្មភាពនិងលទ្ធផលការងាររបស់ការិយាល័យជូនប្រធានឧទ្យានសួនសត្វ និងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅ
- ទទួលភារកិច្ចផ្សេងទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន។

### ៣.៤-ការិយាល័យសង្គ្រោះ និងព្យាបាល

- រៀបចំ និងអនុវត្តផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព និងគម្រោងថវិកាសម្រាប់ការងារសង្គ្រោះ និងព្យាបាល
- គ្រប់គ្រងមន្ទីរពេទ្យសត្វព្រៃ ឱសថ បន្ទប់ព្យាបាល បន្ទប់វះកាត់ បន្ទប់ពិសោធន៍ បន្ទប់រោគវិនិច្ឆ័យ ធ្វើកោសល្យវិច្ច័យ បញ្ចេញ ឬបញ្ចូលឱសថប្រើប្រាស់ ព្យាបាលសត្វ និងកត់ត្រាព័ត៌មាននៃការព្យាបាល
- ថែរក្សា ឬព្យាបាលសត្វចំណូលថ្មី សត្វឈឺ សត្វរបួស ឬសត្វកើតថ្មី
- រៀបចំ និងអនុវត្តកម្មវិធីបង្ការជំងឺឆ្លងសត្វព្រៃគ្រប់ប្រភេទ
- រៀបចំ ឬផ្តល់គោលការណ៍ណែនាំការដឹកជញ្ជូនសត្វព្រៃគ្រប់ប្រភេទ ត្រួតពិនិត្យគុណភាពចំណីសត្វព្រៃ
- ផ្តល់សេវាថែទាំ ព្យាបាល និងសង្គ្រោះសត្វព្រៃ
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំស្តីពីសកម្មភាព និងលទ្ធផលការងាររបស់ការិយាល័យជូនប្រធានឧទ្យានសួនសត្វនិងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅ
- ទទួលភារកិច្ចផ្សេងទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន។

### ៣.៥-ការិយាល័យសេវាកម្ម និងទេសចរណ៍

- រៀបចំ និងអនុវត្តផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព និងគម្រោងថវិកាសម្រាប់ការងារសេវាកម្ម និងទេសចរណ៍
- គ្រប់គ្រងសួនច្បារ រុក្ខជាតិ ដាំរុក្ខជាតិលំអគ្រប់ប្រភេទ
- គ្រប់គ្រងរោងជាង ជួសជុល និងការសាងសង់សំណង់ផ្សេងៗ
- គ្រប់គ្រងសេវាលក់ដូរម្ហូបអាហារ វត្ថុអនុស្សាវរីយ៍ កន្លែងស្នាក់អាស្រ័យ ភោជនីយដ្ឋាន និងការលក់ដូរគ្រប់ប្រភេទ និងនាំភ្ញៀវ
- រៀបចំផលិតសម្ភារផ្សព្វផ្សាយពាណិជ្ជកម្ម និងទីផ្សារ

- បង្កើតព្រឹត្តិការណ៍សួនសត្វ សេវាកំសាន្តសម្រាប់ទេសចរ
- គ្រប់គ្រងសេវាអ្នកស្ម័គ្រចិត្ត និងដៃគូ
- លក់ប័ណ្ណចូលទស្សនាឧទ្យានសួនសត្វភ្នំតាម៉ៅ
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំស្តីពីសកម្មភាពនិងលទ្ធផលការងាររបស់ការិយាល័យជូនប្រធានឧទ្យានសួនសត្វនិងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅ
- ទទួលភារកិច្ចផ្សេងទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

**ប្រការ៤ ._**

ការិយាល័យចំណុះរបស់ឧទ្យានសួនសត្វ និងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅដឹកនាំដោយប្រធានមួយរូបនិងអមដោយអនុប្រធានមួយចំនួនជាជំនួយការ។

ប្រធានការិយាល័យនីមួយៗនៃឧទ្យានសួនសត្វ និងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅត្រូវទទួលខុសត្រូវចំពោះមុខប្រធានឧទ្យានសួនសត្វ និងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅនូវរាល់សកម្មភាពដែលបានអនុវត្តនៅក្នុងការិយាល័យរបស់ខ្លួន។

អនុប្រធានការិយាល័យនីមួយៗ ជាជំនួយការឲ្យប្រធានការិយាល័យត្រូវបានប្រធានការិយាល័យប្រគល់ការងារមួយចំនួនឲ្យទទួលបន្ទុកនិងទទួលខុសត្រូវចំពោះមុខប្រធានការិយាល័យលើរាល់សកម្មភាពការងារ និងរួមគ្នាជាមួយប្រធានការិយាល័យទទួលខុសត្រូវលើរាល់សកម្មភាពការងារក្នុងការិយាល័យ ។

**ប្រការ៥ ._**

ប្រកាស ឬសេចក្តីសម្រេចទាំងឡាយណាដែលមានខ្លឹមសាផ្ទុយពីប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ៦._**

អគ្គលេខាធិការ អគ្គាធិការ ប្រធាននាយកដ្ឋានបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្ស ប្រធាននាយកដ្ឋានគណនេយ្យហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល ប្រធានរដ្ឋបាលព្រៃឈើ និងប្រធានអង្គភាពដែលពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ២កើត ខែ ប.សាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែមិថុនា ឆ្នាំ២០១៨

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

**កន្លែងទទួល ៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

ឧបសម្ព័ន្ធនៃប្រកាសលេខ ២៥៦ ប្រក.កសក.ប ចុះថ្ងៃព្រហ ២កើតខែអាសាឍ ឆ្នាំច សំរឹទ្ធស័ក ព.ស២៥៦២ ត្រូវនឹងថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៨

### អង្គការលេខរបស់ឧទ្យានសួនសត្វ និងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅ នៃរដ្ឋបាលព្រៃឈើ

- ប្រធានឧទ្យានសួនសត្វ និងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅ
  - អនុប្រធានឧទ្យានសួនសត្វ និងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅ
    - ការិយាល័យ រដ្ឋបាល និងហិរញ្ញវត្ថុ
    - ការិយាល័យ អភិរក្ស និងវិបុលកម្ម
    - ការិយាល័យ ស្រាវជ្រាវ អប់រំផ្សព្វផ្សាយ និងសហប្រតិបត្តិការអន្តរជាតិ
    - ការិយាល័យ សង្គ្រោះ និងព្យាបាល
    - ការិយាល័យ សេវាកម្ម និងទេសចរណ៍